NSW GOVERNMENT

# What do I need to know if my child is expelled?

## Parent/carer information

# តើខ្ញុំចាំបាច់ត្រូវដឹងពីអ្វីខ្លះ ប្រសិនបើខ្ញុំត្រូវបានបណ្តេញចេញ?

## ព័ត៌មានសម្រាប់ឪពុកម្តាយ/អ្នកថែទាំ

### តើអ្វីជាការបណ្តេញចេញ?

ការបណ្តេញចេញគឺនៅពេលដែលនាយកសាលា និងនាយក អ្នកដឹកនាំផ្នែកអប់រំប្រាប់សិស្សម្នាក់ថា ពួកគេត្រូវតែចាកចេញពីសាលារៀន ហើយមិនត្រូវត្រឡប់មកវិញទេ។ ការបណ្តេញចេញគឺជាបញ្ហាធ្ងន់ធ្ងរមួយ។ ការប៉ុនប៉ងទាំងអស់គួរតែបានធ្វើឡើងដើម្បីគាំទ្រកូនរបស់អ្នក មុនពេលការសម្រេចចិត្តបណ្តេញចេញត្រូវបានធ្វើឡើង។

នាយកសាលាអាចបណ្តេញចេញសិស្សដោយហេតុផលពីរយ៉ាង៖

- សិស្សបង្ហាញពីអាកប្បកិរិយាធ្ងន់ធ្ងរគួរឱ្យព្រួយបារម្ភ ហើយផែនការគ្រប់គ្រងអាកប្បកិរិយារបស់ពួកគេ មិនបានដំណើរការសោះ។
- សិស្សមានអាយុលើសពី17ឆ្នាំ ហើយមិនបានចូលរួមក្នុងការរៀនសូត្រ។

នាយកសាលានឹងគិតអំពីរបៀបដែលសាលារៀន បានគាំទ្រដល់ការរៀនសូត្ររបស់កូនអ្នក ដោយគិតពិចារណាពីតម្រូវការ និងប្រវត្តិរបស់ពួកគេ មុនពេលពួកគេសម្រេចចិត្តបណ្តេញចេញ។

មុនពេលការបណ្តេញចេញកើតឡើង នាយកសាលានឹងទាក់ទងមកអ្នក ដើម្បីប្រាប់អ្នកឱ្យដឹងថាពួកគេកំពុងគិតចង់បណ្តេញចេញកូនរបស់អ្នក។ ពួកគេនឹងចេញសេចក្តីជូនដំណឹងអំពីការបណ្តេញចេញ ដែលមានសក្តានុពលជាលាយលក្ខណ៍អក្សរមួយ ហើយអញ្ជើញអ្នក និងកូនរបស់អ្នកឱ្យចូលរួមកិច្ចប្រជុំមួយ ដើម្បីផ្តល់ជូនហេតុផលនានា និងនិយាយអំពីអ្វីដែលនឹងកើតឡើង ប្រសិនបើពួកគេបណ្តេញចេញកូនរបស់អ្នក។ អ្នកអាចនាំអ្នកគាំទ្រម្នាក់មកជាមួយអ្នក ដើម្បីចូលរួមកិច្ចប្រជុំនេះ។ អ្នកគាំទ្រអាចផ្តល់ឱ្យអ្នក និង/ឬកូនរបស់អ្នកនូវការគាំទ្រជាក់ស្តែង ឬខាងផ្លូវអារម្មណ៍។

បន្ទាប់ពីកាលបរិច្ឆេទជូនដំណឹងជាលាយលក្ខណ៍អក្សរ អ្នកនឹងមានពេលប្រាំពីរថ្ងៃសិក្សា ដើម្បីផ្តល់ចម្លើយដល់សាលារៀន ជាមួយនឹងហេតុផលនានាដែលកូនរបស់អ្នកមិនគួរត្រូវបានបណ្តេញចេញ។ នាយកសាលានឹងប្រើការឆ្លើយតបនេះជាផ្នែកនៃដំណើរការធ្វើការសម្រេចចិត្ត។

### តើមានអ្វីកើតឡើងប្រសិនបើកូនរបស់ខ្ញុំត្រូវបានបណ្តេញចេញ?

នាយកសាលា និងនាយក អ្នកដឹកនាំផ្នែកអប់រំ នឹងសម្រេចចិត្តរួមគ្នា ប្រសិនបើសិស្សម្នាក់នឹងត្រូវបានបណ្តេញចេញ។ ក្នុងរយៈពេល24 ម៉ោងនៃការសម្រេចចិត្តបណ្តេញចេញសិស្សម្នាក់ នាយកសាលាត្រូវតែប្រាប់សិស្សនោះ និងឪពុកម្តាយ ឬអ្នកថែទាំរបស់ពួកគេ ហើយជូនដំណឹងទៅក្រសួងអប់រំរដ្ឋ NSW។

ប្រសិនបើកូនរបស់អ្នកមានអាយុក្រោម17ឆ្នាំ ហើយត្រូវបានបណ្តេញចេញដោយសារតែអាកប្បកិរិយារបស់ពួកគេ នាយកសាលាត្រូវតែស្វែងរកសាលារៀនថ្មីមួយ ឬកន្លែងជំនួសដើម្បីបន្តការរៀនសូត្រ ក្នុងរយៈពេល15ថ្ងៃសិក្សា។

ប្រសិនបើកូនរបស់អ្នកមានអាយុលើសពី17ឆ្នាំ អ្នក និងកូនរបស់អ្នកគួរតែរកមើលជម្រើសនានាដើម្បីបន្តការរៀនសូត្រ ឬការធ្វើអន្តរកាលទៅកាន់ការងារ។

### តើខ្ញុំអាចទទួលបានព័ត៌មានអ្វីខ្លះពីសាលារៀន

អ្នកអាចសួររកព័ត៌មានបន្ថែមពីសាលារៀន អំពីអ្វីដែលបានកើតឡើង និងមូលហេតុ។ សាលារៀនគួរតែពន្យល់ដល់អ្នកអំពីហេតុផលនៅពីក្រោយការសម្រេចចិត្តណាមួយ សកម្មភាពនឹងកើតឡើង និងអ្វីដែលត្រូវធ្វើប្រសិនបើអ្នកមានបញ្ហា។

### តើខ្ញុំអាចប្តឹងតវ៉ាមិនយល់ស្របចំពោះការបណ្តេញចេញបានទេ?

បាន ប្រសិនបើអ្នកជឿជាក់ថានាយកសាលា និងនាយក អ្នកដឹកនាំផ្នែកអប់រំបានធ្វើការសម្រេចចិត្តមិនយុត្តិធម៌ ឬមិនបានអនុវត្តតាមគោលនយោបាយ និងនីតិវិធីត្រឹមត្រូវ។ សូមយោងទៅធនធានបណ្តឹងតវ៉ាមិនយល់ស្រប។

ព័ត៌មានស្តីពីការតស៊ូមតិសម្រាប់កូនរបស់អ្នកគឺអាចរកបាន ក៏ដូចជាធម្មនុញ្ញសហគមន៍សាលារៀនរបស់យើង ដែលគូសបញ្ជាក់ពីវិធីនានា ដើម្បីប្រាស្រ័យទាក់ទងជាមួយសាលារៀន។

### តើខ្ញុំធ្វើបណ្តឹងតវ៉ាដោយរបៀបណា?

ប្រសិនបើអ្នកមានការព្រួយបារម្ភអំពីការបណ្តេញចេញ ការសម្រេចចិត្តនានាដែលបានធ្វើឡើង ឬការគាំទ្រដែលបានផ្តល់ សូមមើលគេហទំព័រសម្រាប់ព័ត៌មានបន្ថែមអំពីការធ្វើបណ្តឹងតវ៉ា។

### សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកមានបំណងចង់ទាក់ទងមកសាលារៀន ហើយត្រូវការជំនួយផ្នែកភាសាអង់គ្លេស សូមទូរសព្ទទៅសេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទតាមលេខ 131 450 ប្រាប់ពួកគេពីភាសាដែលអ្នកត្រូវការ ហើយស្នើសុំឱ្យការិទូរសព្ទទូរសព្ទទៅសាលារៀន។ ការិទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីជួយអ្នកនៅក្នុងការសន្ទនារបស់អ្នក។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។